# ការប្រើស្រោមលឹង

១. ចូរអ្នកពិគ្រោះជាមួយគូស្នេហាជាមុន អំពីការប្រើស្រោមលឹង។

២. ចូរពិនិត្យនៅលើកញ្ចប់ មើលថ្ងៃខែដែលស្រោមលឹងត្រូវខូច ប្រើមិនបាន។

៣. ចូរសាកល្បងប្រើស្រោមលឹងជាមុន។ ចូរ សាកម៉ាកផ្សេងៗ ជ្រើសរើសរកទំហំអោយបានត្រឹមត្រូវ។

៤. ចូរពាក់ស្រោមលឹង មុននឹងសេពកាម។ ប្រយ័ត្នកុំអោយឆ្កូតដាច់រហែក ដោយសារចិញ្ចៀន រឺក៏ក្រចកដៃ។

៥. ចូរច្បូតស្រោមអោយទៅដល់គល់លឹង។

៦. ចូរកាន់ទប់គល់ស្រោម នៅពេលដែលអ្នកដកលឹងចេញពីយោនី ។

៧. ចូរប្រើធាតុរំអិលដែលមានជាតិទឹក ដូចជាម៉ាក ឃើចេល្លី រឺក៏វេតស្តារ។ ជៀសវាងកុំប្រើធាតុរំអិលដែលមានជាតិប្រេង ដូចជាខ្លាញ់វ៉ាសាលីន រឺក៏ប្រេងទារក(ជាតិប្រេងនេះ ធ្វើអោយខូចស្រោមកៅស៊ូ) ។

៨. ចូរចោលស្រោមលឹងក្នុងធុងសំរាម កុំចោលក្នុងបង្គន់។



*ឥន្ទូរនេះផ្តល់ដោយ គណកម្មការជាតិទីព្រឹក្សា ខាងជំងឺអេតស។*

## NSW SEXUAL HEALTH SERVICES

**Providing free and confidential sexual health care.**

| | |
|---|---|
| Albury | Ph: (02) 6058 1831 |
| Balranald | Ph: (03) 5027 2345 |
| Bourke | Ph: (02) 68722145 |
| Broken Hill | Ph: (08) 8088 5800 |
| Canterbury | Ph: (02) 9718 7655 |
| Coffs Harbour | Ph: (02) 6659 1916 |
| Dubbo | Ph: (02) 6885 1700 |
| Forster | Ph: (02) 6555 6822 |
| Gosford | Ph: (02) 4320 2114 |
| Goulburn | Ph: (02) 4827 3470 |
| Katoomba | Ph: (02) 4780 6060 |
| Kings Cross | Ph: (02) 9360 2766 |
| Kogarah | Ph: (02) 9350 2742 |
| Lightning Ridge | Ph: (02) 68291022 |
| Lismore | Ph: (02) 6620 2980 |
| Liverpool | Ph: (02) 9827 8022 |
| Manly | Ph: (02) 9977 3288 |
| Marrickville | Ph: (02) 9560 3057 |
| Newcastle | Ph: (02) 4923 6909 |
| Nowra | Ph: (02) 4423 9353 |
| Orange | Ph: (02) 6361 9906 |
| Parramatta | Ph: (02) 9843 3124 |
| Penrith | Ph: (02) 4724 2507 |
| Port Kembla | Ph: (02) 4276 2399 |
| Richmond | Ph: (02) 4578 1622 |
| St Leonards | Ph: (02) 9926 7414 |
| Sydney City | Ph: (02) 9382 7440 |
| Tamworth | Ph: (02) 6766 3095 |
| Taree | Ph: (02) 6551 1315 |
| Wagga Wagga | Ph: (02) 6938 6492 |

Khmer

# រោគស្វាយប្រម៉េះ

## Syphillis

SYDNEY SEXUAL HEALTH CENTRE

និង ផ្នែកសិក្សានៃវេជ្ជសាស្ត្រខាងសុខភាពនៃការសេពកាម សាកលវិទ្យាល័យស៊ីដនី/សាកលវិទ្យាល័យញ៉ូសោធវេល

November 1994

## តើគេអាចឆ្លងរោគនេះតាមបែបណា?

ជាធម្មតា រោគស្វាយប្រម៉េះឆ្លងតាមរយៈការសេពកាមតាមយោនី គូថ រឺក៏តាមមាត់ ដោយមិនប្រើស្រោមលឹង ជាមួយអ្នកដែលមានជំងឺនេះ។ រោគនេះអាចឆ្លងនៅពេលមានផ្ទៃពោះ ពីស្រ្តីដែលមានរោគទៅទារកដែលកំពុងចាប់កំណើតក្នុងពោះ។

## តើរោគសញ្ញាមានអ្វីខ្លះ?

ក្នុងដំណាក់ការដំបូង ដំបៅខ្ទុះលេចចេញនៅត្រង់ដែលមានរោគប្រមាណជា១០ទៅ៩០ថ្ងៃក្រោយពេលចំលង។ ធម្មតា ដំបៅនេះមិនធ្វើអោយឈឺចាប់ទេ ហើយដោយសារដំបៅនេះមានទំហំពីតូចដល់ធំ ជួនកាលគេមិនទាំងដឹងចាប់អារម្មណ៍ផងទេ។ ដំបៅនេះជាសះទៅវិញ ក្នុងរយៈពេលពី២ទៅ៦អាទិត្យ។ ដំណាក់ការបន្ទាប់នៃរោគស្វាយ កកើតឡើងក្នុងចន្លោះពេលពី ៧ទៅ១០អាទិត្យក្រោយពេលឆ្លងជាដំបូង។ ក្នុងរយៈពេលនេះ គេនឹងមិនស្រួលខ្លួន ដោយមានអាការរោគដូចជាផ្តាសាយ ហើយមានកន្ទួលរោលពេញខ្លួន ទាំងបាតដៃ បាតជើង និងមុខមាត់ផងដែរ។ ធម្មតា រោគសញ្ញាទាំងនេះមិនធ្ងន់ធ្ងរ ហើយឆាប់បាត់រាបទៅវិញ ម្ល៉ោះហើយគេមិនទាំងដឹងចាប់អារម្មណ៍ផងទេ។

បន្ទាប់មក មេរោគស្វាយនឹងនៅសំងំ។ ក្នុងពេលសំងំនេះ គេពុំឃើញមានអាការរោគអ្វីទេ ហើយមេរោគនេះអាចនៅសំងំយ៉ាងនេះបានរាប់ឆ្នាំ រឺមួយជីវិត។ក្នុងរយៈពេលពី៥ទៅ៣៥ឆ្នាំក្រោយមក អ្នកជំងឺខ្លះអាចនឹងចូលទៅដល់ដំណាក់ការទី៣ ដែលរោគស្វាយនេះនឹងធ្វើអោយខូចសរីរាង្គ មានដូចជាខួរក្បាល ជួរឆ្អឹងខ្នង និងបេះដូង។

## តើគេមានកិច្ចព្យាបាលដែររឺទេ?

នៅពេលដែលគេពិនិត្យដឹងថាជារោគស្វាយហើយនោះ គេអាចព្យាបាលរោគនេះបានយ៉ាងងាយ ដោយការចាក់ រឺលេបថ្នាំអិនទីបាយអូទីក។ រយៈពេលនៃការព្យាបាល នេះនឹងយោលទៅតាមដំណាក់ការនៃជំងឺ ដែលអាចត្រូវការពេលពី១០ទៅ៣០ថ្ងៃ។

## តើគូសេពកាមត្រូវទទួលការព្យាបាលដែររឺទេ?

នេះនឹងយោលទៅលើដំណាក់ការនៃជំងឺ និងរបៀបឆ្លង។ លោកគ្រូពេទ្យនឹងពិគ្រោះអំពីបញ្ហានេះ។

## តើគេអាចអោយអោវាទណាខ្លះទៅអ្នកកើតរោគស្វាយនេះ?

- ព្យាបាលអោយចប់កម្មវិធីត្រឹមត្រូវ។
- អាការរោគបែបផ្តាសាយ ជាប្រតិកម្មធម្មតា ក្នុងកំលុងថ្ងៃដំបូងនៃកម្មវិធីព្យាបាល។ អាការរោគទាំងនេះ ពុំមានន័យថា អ្នកជំងឺមានប្រតិកម្មពីថ្នាំអិនទីបាយអូទីកនោះឡើយ
- ប្រសិនបើគេចេញជាកន្ទួលរោលពេញខ្លួន រឺក៏មានរោគសញ្ញាអែទៀត ក្រោយពីថ្ងៃទីមួយនៃកម្មវិធីព្យាបាល គេគួរតែប្រាប់ក្រុមពេទ្យអោយដឹង។រោគសញ្ញាទាំងនេះអាចគេដឹងអំពីប្រតិកម្មរបស់ថ្នាំ។
- ក្រោយពីការព្យាបាលបានចប់សព្វគ្រប់ហើយ គេនឹងស្នើសុំអោយអ្នកជំងឺយកឈាមទៅបំបែកវិភាគពិនិត្យមើល។ គេចង់អោយច្បាស់ថា ការព្យាបាលជំងឺនេះបានជោគជ័យហើយ។
- ធម្មតា គេអាចអនុញ្ញាតអោយសេពកាមឡើងវិញក្រោយពីអាទិត្យទីមួយនៃការព្យាបាល។ ចូរសួរក្រុមពេទ្យ។

## តើការបំបែកវិភាគឈាមក្រោយពេលព្យាបាលនឹងចេញលទ្ធផលជានេហ្គាទីវ (Negative) បន្ទាប់ពីកម្មវិធីព្យាបាល?

គេបានដឹងថា អ្នកជំងឺណាម្នាក់កើតរោគស្វាយ ដោយសារ ការបកស្រាយការបែងវិភាគធាតុប្រឆាំងប្រចាំកាយមួយចំនួន ដែលគេធ្វើឡើងដោយយកឈាមតែម្តងទៅមើល។ ធម្មតា ការបែងវិភាគពីរដងបែបនេះនឹងចេញជាលទ្ធផលប៉ូស៊ីទីវមួយជីវិត។ គេស្គាយដោយធាតុប្រឆាំងប្រចាំកាយទាំងនោះ ពុំអាចការពារមិនអោយរោគស្វាយ នេះកកើតឡើងវិញបាន។